# ការពិនិត្យមាត់ស្បូន

## ការធ្វើតេស្តរបស់អ្នក គឺជាជម្រើសរបស់អ្នក

TimeToCervicalScreen.nz

មានសុវត្ថិភាព

លទ្ធផលត្រឹមត្រូវ

Time to screen National Cervical Screening Programme

## មេរោគ HPV និងជំងឺមហារីកមាត់ស្បូន

ជំងឺមហារីកមាត់ស្បូន ស្ទើរតែទាំងអស់ គឺបណ្តាលមកពីវីរុសដែលឆ្លងជំងឺលើស្បែក និងភ្នាសរអិល (HPV) ។ មេរោគនេះ គឺជាមេរោគសាមញ្ញដែលគេស្គាល់ជាទូទៅ ហើយវាឆ្លងតាមរយៈការប៉ះពាល់ស្បែកនឹងស្បែក ឬតាមរយៈសកម្មភាពរួមភេទ ។ មនុស្សពេញវ័យស្ទើរតែទាំងអស់ នឹងកើតជំងឺ HPV នៅដំណាក់កាល ណាមួយក្នុងជីវិតរបស់ពួកគេ ។

ខណៈពេលដែលករណីជំងឺ HPV ភាគច្រើនជាធម្មតាបាត់ទៅវិញដោយខ្លួនវា ក៏មេរោគខ្លះ វានៅបន្ត ហើយធ្វើឲ្យកោសិកាប្រែប្រួល ដែលអាចប្រែទៅជាជំងឺមហារីក នៅពេលនោះតែម្តង ។ ជួនកាល មេរោគនេះ វាក៏អាចនៅស្ងៀមនៅក្នុងប្រព័ន្ធរាងកាយរបស់អ្នក ហើយពេទ្យអាចពិនិត្យមិនឃើញ ក្នុងពេលដំបូង រហូតដល់រាប់ឆ្នាំក្រោយពីអ្នកបានឆ្លងវា ។ ប្រសិនបើ ពេលធ្វើតេស្ត ទៅឃើញមេរោគនេះ មិនមែនមានន័យថាអ្នកទើបប្រឈមនឹងមេរោគ HPV កាលពីពេលថ្មីៗឡើយ ។ ដោយសារហេតុផលទាំងនេះហើយ ទើបការបន្តពិនិត្យជាប្រចាំ គឺមានសារៈសំខាន់ទោះបីជាអ្នកមិនដូរដៃគូរួមភេទ ឬមិនបានរួមភេទមួយរយៈក៏ដោយ ។

ជាធម្មតា មេរោគនេះ ចំណាយពេលរហូតដល់ 10 ឆ្នាំ ឬច្រើនជាងនេះ ដើម្បីវិវឌ្ឍន៍ខ្លួនវាទៅជាជំងឺមហារីកមាត់ស្បូន ។ ការពិនិត្យជាទៀងទាត់អាចរកឃើញ មនុស្សដែលស្ថិតក្នុងហានិភ័យខ្ពស់ ពីការវិវត្តន៍នៃការផ្លាស់ប្តូរកោសិកា ដូច្នេះប្រសិនបើការផ្លាស់ប្តូរនៃកោសិកាទាំងនោះ ពិតជាកើតឡើងមែន ពួកគេនឹងបានទទួលការព្យាបាល ហើយជាញឹកញាប់ គឺបានទទួលការព្យាបាល មុនពេលដែលការប្រែប្រួលនេះក្លាយជាជំងឺមហារីក ។

គឺមានដំណាក់កាលជាច្រើន ចាប់ពីការឆ្លងមេរោគ HPV ការផ្លាស់ប្តូរកោសិកា និងការកកើតជំងឺមហារីក ។ ការមានមេរោគ HPV នៅក្នុងខ្លួន មិនមែនមានន័យថា អ្នកមានជំងឺមហារីកឡើយ ។

មហារីកមាត់ស្បូន ជាមហារីកមួយក្នុងចំណោមមហារីកជាច្រើនដែលយើងអាចការពារបានច្រើនបំផុត ។ ការចាក់ថ្នាំបង្ការមេរោគ HPV និងការពិនិត្យជាទៀងទាត់ អាចជួយការពារអ្នកបានប្រសើរបំផុត ពីការវិវឌ្ឍន៍ជាជំងឺមហារីកមាត់ស្បូន ។

ស្ត្រីប្រហែល 90% ដែលបានពិនិត្យ គឺនឹងរកមិនឃើញមេរោគ HPV ឡើយ ហើយពួកគេអាចគ្រាន់តែបន្តការពិនិត្យជាប្រចាំ តែប៉ុណ្ណោះ ។ ស្ត្រីប្រហែល 10% ដែលបានពិនិត្យ នឹងរកឃើញមានមេរោគ HPV នៅក្នុងខ្លួន នឹងត្រូវទទួលការពិនិត្យបន្ថែមទៀត ។

## អំពីការពិនិត្យមាត់ស្បូន

ទន្ទឹមនឹងការចាក់វ៉ាក់សាំងបង្ការមេរោគ HPV ការពិនិត្យមាត់ស្បូនជាទៀងទាត់ គឺអាចជួយកាត់បន្ថយមិនឲ្យអ្នកធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារជំងឺមហារីកមាត់ស្បូន ។ ការចូលរួម ជាផ្នែកមួយនៃកម្មវិធីជាតិពិនិត្យមាត់ស្បូន (National Cervical Screening Program - NCSP) និងការពិនិត្យជាប្រចាំ គឺជាមធ្យោបាយដ៏ល្អបំផុត ដើម្បីការពារខ្លួនអ្នក ពីជំងឺមហារីកមាត់ស្បូន ដើម្បីជួយឲ្យអ្នកមានសុខភាពល្អ សម្រាប់ខ្លួនអ្នក និងក្រុមគ្រួសាររបស់អ្នក ។

ឥឡូវ យើងមានរបៀបធ្វើតេស្តពិនិត្យមាត់ស្បូន បានឆាប់រហ័ស ហើយងាយស្រួល ដែលស្ត្រីភាគច្រើន ត្រូវធ្វើតេស្ត រៀងរាល់ 5 ឆ្នាំម្តង ដោយមានជម្រើស ចំពោះការធ្វើតេស្តដោយខ្លួនឯង ផងដែរ ។

ការធ្វើតេស្តមេរោគ HPV គឺមានភាពរសើប និងត្រឹមត្រូវ ក្នុងការរកឃើញមេរោគ ដែលបណ្តាលឱ្យកើតមហារីកមាត់ស្បូនភាគច្រើន ។ មធ្យោបាយនេះ គឺអាចជួយរកឃើញស្ត្រីប្រហែល 10% ក្នុងចំណោមអ្នកដែលចូលពិនិត្យ ដែលស្ថិតក្នុងហានិភ័យខ្ពស់ ចំពោះការវិវត្តកោសិកាមុនវាក្លាយទៅជាមហារីកមាត់ស្បូន ដែលអាចជួយឲ្យពួកគេទទួលបានការព្យាបាលទាន់ពេលវេលា និងការពារពួកគេ កុំឲ្យកើតជំងឺមហារីកមាត់ស្បូន ។

វិធីសាស្ត្រថ្មីនៃការពិនិត្យមាត់ស្បូន រកមើលមេរោគធម្មតាមួយ ដែលហៅថាមេរោគឆ្លងនៅលើស្បែក (HPV) ដែលបណ្តាលឲ្យកើតជំងឺមហារីកមាត់ស្បូនច្រើនជាង 95% ។ ការធ្វើតេស្តនេះ គឺចេញលទ្ធផលល្អដូចគ្នា មិនថាអ្នកធ្វើវាដោយខ្លួនឯង ឲ្យអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកជួយ ឬឲ្យគេប្រមូលសំណាកមាត់ស្បូន នោះឡើយ ។




## តើខ្ញុំអាចដឹងដោយរបៀបណាថា ខ្ញុំត្រូវការពិនិត្យមាត់ស្បូន?

អ្នកត្រូវពិនិត្យមាត់ស្បូន ប្រសិនបើអ្នក ៖

- ជាស្ត្រី ឬជាមនុស្សដែលមានស្បូន
- អាយុរវាង 25 ទៅ 69 ឆ្នាំ
- មានការរួមភេទនាពេលបច្ចុប្បន្ន ឬពីមុន ។

ប្រសិនបើអ្នកបានវះកាត់ស្បូនចេញអស់ (ការកាត់ស្បូន និងមាត់ស្បូនចេញ) សូមសាកសួរ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ថាតើវាចាំបាច់សម្រាប់អ្នក ក្នុងការពិនិត្យមាត់ស្បូនដែរឬទេ ។

ប្រសិនបើអ្នកមានផ្ទៃពោះ ក៏មិនមានបញ្ហាក្នុងការពិនិត្យមាត់ស្បូនដែរ ។ បើអ្នកមករដូវ ក៏អ្នកនៅតែអាចធ្វើតេស្តបានដែរ ដរាបណាការហូរឈាមមិនច្រើនពេកទេ ព្រោះវាអាចប៉ះពាល់ដល់លទ្ធផលតេស្ត ។

## ជម្រើសរបស់អ្នក ក្នុងការធ្វើតេស្តមេរោគ HPV

មានជម្រើសពីរ ចំពោះរបៀបធ្វើតេស្តពិនិត្យមាត់ស្បូន ។ សំណាករបស់អ្នកអាចប្រមូលជាសំណាកដងសំឡីរុកចូលតាមទ្វារមាស (ដែលអាចធ្វើបានជាលក្ខណៈការធ្វើតេស្តដោយខ្លួនឯង ឬដោយមានជំនួយពីអ្នកផ្តល់សេវាថែទាំសុខភាព) ឬប្រមូលជាសំណាកមាត់ស្បូន (គឺជាអ្វីដែលគេធ្លាប់ស្គាល់ថាជាការធ្វើតេស្តមាត់ស្បូន) ។

### ជម្រើសទី 1 នៃការធ្វើតេស្តមេរោគ HPV ៖ ប្រើដងសំឡីស៊កចូលតាមទ្វារមាស

ការធ្វើតេស្ត ដោយប្រើដងសំឡីស៊កចូលតាមទ្វារមាស គឺសាកសមចំពោះស្ត្រីភាគច្រើន ។ ពេទ្យ នឹងណែនាំអ្នក ប្រសិនបើមាន របៀបធ្វើតេស្តផ្សេងទៀត ដែលសមរម្យបំផុតសម្រាប់អ្នក ។

ការធ្វើតេស្តដោយខ្លួនឯង ជាធម្មតាគេធ្វើ នៅកន្លែងឯកជន មិនមានអ្នករំខាន ទៅតាមការណាត់ ជួបពេទ្យពិនិត្យ របស់អ្នក ។ អ្នកទទួលការធ្វើតេស្តខ្លះ ផ្តល់ការធ្វើតេស្តនៅទីតាំងរបស់សហគមន៍ រថយន្តធ្វើតេស្តចល័ត ឬជម្រើសយកទៅធ្វើតេស្តនៅផ្ទះ ។

ប្រសិនបើអ្នក ចង់ឱ្យអ្នកទទួលធ្វើតេស្ត ជួយក្នុងការសើកដងសំឡីចូលទ្វារមាស សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ឲ្យបានដឹងនៅពេលអ្នកណាត់ជួបពួកគេ ដើម្បីធ្វើតេស្ត ។

សំណាកនេះ នឹងត្រូវប្រមូលពីក្នុងទ្វារមាសរបស់អ្នក ដោយប្រើដងសំឡី ។ សំណាកប្រមូលពីទ្វារមាស គឺសម្រាប់តែធ្វើតេស្ត រកមេរោគ HPV តែប៉ុណ្ណោះ ។




បើគេរកឃើញមេរោគ HPV, អាស្រ័យលើប្រភេទដែលបានរកឃើញ, ពេទ្យអាចយកសំណាកមាត់ស្បូនរបស់អ្នក (ដែលពីពេលមុនគេហៅថាការធ្វើតេស្តមាត់ស្បូន) ដើម្បីពិនិត្យមើលការផ្លាស់ប្តូរកោសិកាណាមួយ ឬក៏ពេទ្យអាចបញ្ជូនអ្នក ឲ្យទៅពិនិត្យផ្នែកខាងក្នុងនៃរន្ធទ្វារមាស ដើម្បីរកមើលថាតើ មានការផ្លាស់ប្តូរណាមួយចំពោះមាត់ស្បូន ដែលត្រូវធ្វើការព្យាបាលដែរឬទេ ។

ប្រសិនបើគេរកមិនឃើញមេរោគ HPV ទេ ពេទ្យនឹងណែនាំឲ្យអ្នកមកពិនិត្យម្តងទៀត 5 ឆ្នាំក្រោយ (ឬ 3 ឆ្នាំក្រោយ ប្រសិនបើអ្នកមានភាពស៊ាំចុះខ្សោយ) ។

ព័ត៌មានបន្ថែមអំពីការធ្វើតេស្តទ្វារមាសដោយប្រើដងសំឡីមាននៅ **www.CervicalSelfTest.nz**

### ជម្រើសទី 2 នៃការធ្វើតេស្ត HPV ៖ យកសំណាកមាត់ស្បូន

វិធីនេះ កាលពីមុនគេហៅថាការធ្វើតេស្តមាត់ស្បូន (smear test)។ ពេទ្យអាចណែនាំឲ្យស្ត្រីខ្លះពិនិត្យមាត់ស្បូនដោយវិធីនេះ ហើយអ្នកក៏អាចជ្រើសយកវិធីនេះដែរ បើអ្នកចង់ ។

ការយកសំណាកមាត់ស្បូន ត្រូវធ្វើឡើងដោយពេទ្យជំនាញ ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ។ ការយកសំណាកនេះ អាចធ្វើនៅគ្លីនិក ទីតាំងសហគមន៍ ឬនៅក្នុងរថយន្តចល័ត ។

អ្នកទទួលពិនិត្យ នឹងប្រមូលសំណាកកោសិកាពីមាត់ស្បូនរបស់អ្នក ដោយប្រើឧបករណ៍ចំពុះទា និងជក់តូចមួយ ។ សំណាកនេះ ត្រូវគេពិនិត្យរកមើលមេរោគ HPV មុនគេ ។




ប្រសិនបើគេរកឃើញមេរោគ HPV គេត្រូវយកសំណាកនេះ ទៅពិនិត្យរកមើល ការផ្លាស់ប្តូរកោសិកាណាមួយ ។ អាស្រ័យលើលទ្ធផលដែលចេញមក ពេទ្យអាចបញ្ជូនអ្នកឲ្យទៅពិនិត្យផ្នែកខាងក្នុងនៃរន្ធទ្វារមាស ដើម្បីរកមើលថាតើមានការផ្លាស់ប្តូរស្ថានភាពរបស់មាត់ស្បូន ដែលត្រូវការការព្យាបាលដែរឬទេ ។

ប្រសិនបើគេរកមិនឃើញមេរោគ HPV ទេ ពេទ្យនឹងណែនាំឲ្យអ្នកមកពិនិត្យម្តងទៀត 5 ឆ្នាំក្រោយ (ឬ 3 ឆ្នាំក្រោយ ប្រសិនបើអ្នកមានភាពស៊ាំចុះខ្សោយ) ។

ព័ត៌មានបន្ថែមអំពីសំណាកមាត់ស្បូនមាននៅឯ **www.CervicalSample.nz**

## តើខ្ញុំអាចចូលរួមកម្មវិធីពិនិត្យមាត់ស្បូនដោយរបៀបណា?

អ្នកនឹងក្លាយជាផ្នែកនៃកម្មវិធីនេះ ដោយស្វ័យប្រវត្តិ ប្រសិនបើអ្នកត្រូវតាមលក្ខណៈវិនិច្ឆ័យរបស់កម្មវិធី ពេលអ្នកមានអាយុ 25 ឆ្នាំ ឬបានធ្វើតេស្តពិនិត្យមាត់ស្បូនលើកដំបូង ។

ដើម្បីបានទទួលការអញ្ជើញឲ្យមកពិនិត្យ រំឭក ឬបញ្ជាក់អំពីការមកពិនិត្យម្តងទៀត អ្នកត្រូវមានឈ្មោះក្នុងបញ្ជី NCSP ។ ប្រសិនបើអ្នកមិនប្រាកដថាអ្នកមានឈ្មោះក្នុងបញ្ជីនេះឬទេ សូមទូរស័ព្ទទៅលេខ **0800 729 729** ។

## តើខ្ញុំមានសិទ្ធិទទួលបានការពិនិត្យដោយឥតគិតថ្លៃដែរឬទេ?

កម្មវិធីជាតិពិនិត្យមាត់ស្បូន (NCSP) មិនបានទទួលជំនួយថវិកាពេញលេញឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ ការពិនិត្យមាត់ស្បូន គឺមិនគិតថ្លៃទេ សម្រាប់ស្ត្រី និងអ្នកដែលមានមាត់ស្បូនដែល ៖

- មានអាយុចាប់ពី 30 ឆ្នាំឡើងទៅ ហើយមិនដែលមានការធ្វើតេស្តពីមុន ឬជាមនុស្សស្ថិតក្នុងការតាមដានពិនិត្យ
- ត្រូវធ្វើតេស្ត ដើម្បីតាមដានស្ថានភាពមាត់ស្បូន
- កាន់ប័ណ្ណសេវាសហគមន៍
- គឺជនជាតិ Maori ឬអ្នកកោះប៉ាស៊ីហ្វិក ។

## តើខ្ញុំទៅពិនិត្យមាត់ស្បូននៅឯណា?

ជម្រើសរបស់អ្នក រួមមាន ៖

- គ្រូពេទ្យ ឬគិលានុបដ្ឋាយិកា ដែលអ្នកជួបជាប្រចាំ នៅគ្លីនិក GP ប្រសិនបើអ្នកធ្លាប់ជួបពួកគេពីមុន
- មជ្ឈមណ្ឌលសុខភាពសហគមន៍ជនជាតិ Maori, អ្នកកោះ ប៉ាស៊ីហ្វិក ឬមណ្ឌលសុខភាពសហគមន៍ស្ត្រី
- សេវាផ្សព្វផ្សាយ ដូចជាទីធ្លាវេទិកាសង្គម ឬអង្គភាពចល័ត
- គ្លីនិកពន្យារកំណើត
- សេវាសុខភាពផ្លូវភេទ (ជាផ្នែកនៃការជួបពេទ្យ ពិគ្រោះជំងឺពេញលេញ) ។

អ្នកផ្តល់សេវាថែទាំសុខភាពមួយចំនួន អាចផ្តល់ជម្រើសឲ្យយកទៅធ្វើតេស្តនៅផ្ទះ សូមពិភាក្សាជាមួយពួកគេ ប្រសិនបើអ្នកចាប់អារម្មណ៍ចំពោះជម្រើសនេះ ។

អ្នកអាចនាំអ្នកដែលអាចជួយអ្នក មកជាមួយបានដែរ ពេលមកជួបពេទ្យ ។ នៅពេលអ្នកកំណត់ពេលជួបពេទ្យ សូមប្រាប់គេឲ្យបានដឹងថា តើអ្នកត្រូវការអ្នកបកប្រែដែរឬទេ ឬប្រាប់គេឲ្យដឹង បើអ្នកមានពិការភាពជាប់ខ្លួនដែលមានន័យថា អ្នកត្រូវការជំនួយ ។

## ស្វែងយល់បន្ថែម

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីនេះ, មេរោគ HPV និងមហារីកមាត់ស្បូន, ជម្រើសរបស់អ្នកក្នុងការធ្វើតេស្ត និងកន្លែងណាត់ជួបពេទ្យ សូមចូលទៅកាន់គេហទំព័រ **www.TimeToCervicalScreen.nz** ឬទូរស័ព្ទឥតគិតថ្លៃទៅលេខ **0800 729 729** ពីម៉ោង 8 ព្រឹក ដល់ 8 យប់ ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ និងម៉ោង 9 ព្រឹក ដល់ 1 រសៀលនៅថ្ងៃសៅរ៍ ឬតាមអ៊ីមែល **screening@health.govt.nz**

ប្រសិនបើអ្នកថ្លង់ ពិបាកស្តាប់ ថ្លង់ហើយពិការភ្នែក ពិការការនិយាយ ឬពិបាកនិយាយ អ្នកអាចប្រើសេវា New Zealand Relay Service ៖ **www.nzrelay.co.nz**


TimeToCervicalScreen.nz

Health New Zealand
Te Whatu Ora

Te Kāwanatanga o Aotearoa
New Zealand Government

HE1342 March 2024 - KHMER